# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ០៧១ ក.ក.ប.វ /ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦

## ប្រកាស

## ស្តីពី

## ការចុះបញ្ជិកានៃអង្គការវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## សម្រេច

### ប្រការ ១.-

ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ស្តីពីការងារទទួលស្គាល់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការ ដឹកនាំ និង

កិច្ចការរដ្ឋបាលទៅតំកល់ទុកទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំចុះបញ្ជិកា ។

**ប្រការ ២.-**

សំណុំលិខិតស្នើសុំចុះបញ្ជិកាមានដូចតទៅ ÷

១- ពាក្យស្នើសុំចុះបញ្ជិកាដោយមានចុះហត្ថលេខា និងនាមរបស់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈ.... ០១ ច្បាប់ ។

២- លក្ខន្តិកៈ " ច្បាប់ដើម " របស់អង្គការវិជ្ជាជីវៈ.......................................................... ០២ច្បាប់ ។

៣- បញ្ជីរាយនាមអ្នកទទួលខុសត្រូវការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាល ដោយបញ្ជាក់អំពីភេទ សញ្ជាតិ ឆ្នាំកំណើត កំរិតវប្បធម៌ មុខងារ អតីតភាពក្នុងវិជ្ជាជីវៈ ឬមុខរបរ និងអាសយដ្ឋានច្បាស់លាស់ ។ ចំពោះអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលដែលមានសញ្ជាតិខ្មែរ ត្រូវភ្ជាប់ទៅជាមួយនូវ " លិខិតប្រកាសផ្ទាល់ខ្លួន " ដែលមានចុះកាលបរិច្ឆេទច្បាស់លាស់ និងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំទទួលខុសត្រូវផង ដោយប្រកាសបញ្ជាក់ដោយខ្លួនឯងថា មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយឡើយ ។ សេចក្តីប្រកាសផ្ទាល់ខ្លួននេះត្រូវមានសុពលភាពមិនលើសពីបីខែ គិតរហូតដល់ថ្ងៃទទួលសំណុំលិខិត ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើលិខិតជាផ្លូវការទៅក្រសួងមានសមត្ថកិច្ច ដើម្បីបញ្ជាក់ថា សាមីជនទាំងអស់ខាងលើ ពិតជាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយទេ ។ ករណីក្រសួងមានសមត្ថកិច្ច ចេញសេចក្តីបញ្ជាក់ជាផ្លូវការថាសាមីជនណាធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយនោះ អង្គការវិជ្ជាជីវៈនោះ ត្រូវតែធ្វើការផ្លាស់ប្តូរសមាសភាពថ្មីមកជំនួសជននោះជាដាច់ខាត ដោយអនុវត្តតាមបែបបទដូចមានចែងខាងលើនេះដែរ ។

ចំពោះអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលដែលមានសញ្ជាតិបរទេស ត្រូវភ្ជាប់ទៅជាមួយនូវលិខិតជាច្បាប់ដើម ឬសេចក្តីថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់នូវលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចអំពីសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ត្រឹមត្រូវតាមច្បាប់អន្តោប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

៤- កំណត់ហេតុនៃការបង្កើតអង្គការវិជ្ជាជីវៈ " ច្បាប់ដើម " ................................................ ០១ ច្បាប់ ។

សំណុំលិខិតសុំចុះបញ្ជិកាខាងលើ ត្រូវផ្ញើរទៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក " ផ្លូវ ១៨៤ " សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ ៣.-**

គ្រប់អង្គការវិជ្ជាជីវៈត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលចម្លងជូនទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃខេត្ត-ក្រុង មូលដ្ឋានខ្លួន ព្រមទាំងចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃផង ។

ប្រការ ៤.~

រាល់ការផ្លាស់ប្តូរលក្ខន្តិកៈ ឬអ្នកគ្រប់គ្រង ដឹកនាំអង្គការវិជ្ជាជីវៈ ក៏ដូចជាការរំលាយអង្គការវិជ្ជាជីវៈ ត្រូវតែរាយការណ៍ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នដទៃទៀត ដូចមានចែងក្នុងប្រការ ៣ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ បន្ទាប់ពីមានការផ្លាស់ប្តូរទាំងនោះ ឬក្រោយការរំលាយអង្គការវិជ្ជាជីវៈ ។

ប្រការ ៥.~

ដើម្បីឱ្យមានការងាយស្រួលក្នុងការពិនិត្យ មុនចុះបញ្ជិកាលក្ខន្តិកៈនៃអង្គការវិជ្ជាជីវៈ សូមបញ្ជាក់ឱ្យបានច្បាស់លាស់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាននូវចំណុចជាអាទិ៍ ដូចតទៅ ÷

១- ឈ្មោះនៃអង្គការវិជ្ជាជីវៈ

២- ទីស្នាក់ការនៃអង្គការវិជ្ជាជីវៈ

៣- គោលបំណងរបស់អង្គការវិជ្ជាជីវៈ

៤- លក្ខខណ្ឌចូលជាសមាជិក និងបណ្តេញចេញពីសមាជិក អង្គការវិជ្ជាជីវៈ

៥- បែបបទបោះឆ្នោតជ្រើសរើស ឬបណ្តេញចេញអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាល និងគណៈកម្មការ ។ បែបបទបោះឆ្នោតកំណត់អាណត្តិ និងបែបបទបន្តអាណត្តិថ្មី នៃអង្គការវិជ្ជាជីវៈ

៦- បែបបទនៃការបោះឆ្នោតជាសម្ងាត់សម្រាប់ធ្វើកូដកម្ម ឬឡុកអៅ

៧- សាមយិកភាព នៃមហាសន្និបាត និងនីតិវិធីនៃការពិភាក្សា

៨- អត្រានៃភាគទានគ្រាដំបូង របៀបបង់ភាគទាននៅពេលបន្ទាប់មកទៀត

៩- នីតិវិធីនៃការគ្រប់គ្រងគណនី

១០- នីតិវិធីគ្រោងទុកសម្រាប់ការកែប្រែលក្ខន្តិកៈ

១១- នីតិវិធីនៃការរំលាយអង្គការវិជ្ជាជីវៈ និងការបែងចែកទ្រព្យសម្បត្តិរួមរបស់អង្គការវិជ្ជាជីវៈ ។

ចំណុចទាំង ១១ ខាងលើនេះ គ្រាន់តែជាចំណុចជួយណែនាំដល់អ្នកតាក់តែងលក្ខន្តិកៈ នៃអង្គការវិជ្ជាជីវៈតែប៉ុណ្ណោះ ។ អង្គការវិជ្ជាជីវៈ មានសិទ្ធិតាក់តែងលក្ខន្តិកៈរបស់ខ្លួនបានដោយសេរី កុំឱ្យតែលក្ខន្តិកៈនោះផ្ទុយជាមួយច្បាប់ជាធរមាន ឬផ្ទុយជាមួយសណ្តាប់ធ្នាប់សាធារណៈ ។

ប្រការ ៦.~

សហភាពអង្គការវិជ្ជាជីវៈទាំងឡាយ ក៏ត្រូវបំពេញសំណុំលិខិតស្នើសុំចុះបញ្ជិកា ដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះផងដែរ ក្នុងលក្ខខណ្ឌដែលសហភាពទាំងនោះ ត្រូវផ្តល់ឱ្យបានដឹងនូវឈ្មោះ និងទីស្នាក់ការរបស់សហជីពដែលជាសមាជិករបស់ខ្លួន ។

សហភាពអង្គការវិជ្ជាជីវៈ ក៏ត្រូវអនុវត្តបទប្បញ្ញត្តិនៃប្រការ ៣ នៃប្រកាសនេះផងដែរ ។

**ប្រការ ៧.-**

ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ ២២១ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ និងលេខ ២៧៧ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ញ៉ែប ប៊ុនជិន

<u>ចម្លងជូន</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

  "ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ